P.K_1
1974-6




# កម្ពុជសុរិយា

ក្រុម...ទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

មស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

ចាត់ចែងបោះពុម្ពផ្សាយដោយគណៈកម្មការមួយ មាន៖

នាយកការផ្សាយ ៖ **អ៊ុក - សាម៉ន**

អ្នករៀបចំ **គួច ឌៃ**

គណៈកម្មការទិពន្ធ ៖

ព្រះពោធិវង្ស **ស៊ួរ-ហាយ**

លោក **ផល - និត** អ្នកស្រី **ពេជ៌ - សល់**

ផ្នែកសាសនា

# ពុទ្ធសាសនា

ដោយព្រះសិរីសម្មតិវង្ស គង់-គូ

ទស្សនាវដ្ដីកម្ពុជសុរិយា

ឆ្នាំទី៤៦ ខែមិថុនា ព.ស.២៥១៨ គ.ស.១៩៧៤



ព្រះសិរីសម្មតិវង្ស គង់ គូ បិយសីលោ
អតីតចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត
និងជាក្រុមជំនុំប្រែព្រះត្រៃបិដកខ្មែរ

ផ្នែកសាសនា

# ពុទ្ធសាសនា

ដោយព្រះសិរីសម្មតិវង្ស គង់-គូ

ព្រះសម្ពុទ្ធបរមគ្រូប្រសូតនៅសម័យប្រហែល៥៦៧ឆ្នាំ[១]មុនគ.ស. ហើយទ្រង់ចូលបរិនិព្វានប្រហែល៤៨៧ឆ្នាំមុនគ.ស.។ ពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ឋិតនៅរហូតមកដល់សព្វថ្ងៃនេះ, ប៉ុន្តែ នៅក្នុងរជ្ជកាលនៃស្តេចកនិស្ក គឺខាងដើមនៃគ្រិស្តសករាជ យើងឃើញវិជ្ជាស្ថានថ្មីនៃពុទ្ធសាសនា មានឈ្មោះថា "មហាយាន" បានឧប្បត្តិឡើង។ នៅក្នុងចំណោមអ្នកគាំទ្រទាំងឡាយខ្ពង់ខ្ពស់នៃគោលគំនិត និងទស្សនវិជ្ជាមហាយាន មានឈ្មោះ នាគាជុន, វសុពន្ធ, អសង្គៈ និង ធម៌កិរ្តិ។

សាសនាមហាយាន ត្រូវបានគេរៀបចំធ្វើសង្គាយនាម្តង ក្រោមការដឹកនាំនៃវសុមិត្រនិងអស្វឃោស នៅក្នុងរដ្ឋកស្មីរ ក្រោមការឧបត្ថម្ភនៃស្តេចកនិស្ក ដើម្បីដោះស្រាយបញ្ហាខ្លះដែលកើតឡើង អំពីការជជែងយោបល់គ្នា រវាងអ្នកប្រាជ្ញសវាស្តិវាទិននៅក្នុងរដ្ឋកស្មីរនិងគន្ធារ ហើយនឹងដើម្បីចងក្រងអដ្ឋកថាជាពិស្តារបីគម្ពីរសម្រាប់ព្រះត្រៃបិដក គឺៈ

---

១-តាមការគណនារបស់អ្នកប្រវត្តិវិទ្យាប៉ែកប្រទេសខាងលិច។

១-ឧបទេសសាស្ត្រ សម្រាប់សុត្តន្តបិដក។

២-វិនយវិភាសាសាស្ត្រ សម្រាប់វិន័យបិដក។

៣-អភិធម្មវិភាសាសាស្ត្រ សម្រាប់អភិធម្មបិដក។

ឯលក្ខណៈមហាយាន ដែលប្លែកពីថេរវាទគឺៈ

១–ថេរវាទសម្តែងថា មនុស្សយើងត្រូវប្រាថ្នាយកព្រះអរហត្តនិង ព្រះនិព្វាន, ឯមហាយានសម្តែងថា មនុស្សត្រូវប្រាថ្នាយកភាពនៃពោធិ-សត្វដែលមានពោធិញាណជាទីបំផុត។

២–ថេរវាទថា មនុស្សបានសម្រេចព្រះនិព្វាន ដោយសារបុញ្ញ-កិរិយាវត្ថុ, ឯមហាយានថា មនុស្សបានសម្រេចព្រះនិព្វាន ដោយជំនឿនិង ភក្តីភាពចម្ពោះព្រះពុទ្ធ មានព្រះពុទ្ធអមិតាភៈជាដើម។

៣–ថេរវាទថា មនុស្សបានសម្រេចព្រះនិព្វាន ដោយសារសេចក្តី ព្យាយាមរបស់ខ្លួន, ឯមហាយានថា គេបានសម្រេចនិព្វានដោយសារភក្តី ភាពនិងការគោរពចម្ពោះព្រះពុទ្ធ។ (ដោយសារគំនិតនេះឯង ទើបពួក មហាយាន បានបង្កើតពុទ្ធរូបសម្រាប់គោរពបូជា)។

៤–ក្នុងគំនិតពួកមហាយានថា ព្រះពុទ្ធទាំងឡាយ មានរូបអាស្រ័យ នៅដេរដាសពាសពេញគ្រប់កន្លែងក្នុងអាកាស ដោយសារកម្លាំងឈាន ដូចជាព្រះពុទ្ធភៃសជ្យគុរុនិងអមិតាភៈ។ ព្រះពុទ្ធអមិតាភៈ ស្ថិតនៅទិស

ខាងលិច ក្នុងឋានសួគ៌ឈ្មោះសុខាវតី។

៥–ព្រះពុទ្ធ១អង្គ មានកាយ៣ គឺ ១-ធម៌កាយ គឺកាយព្រះធម៌ បានដល់ព្រះពោធិ ឬនិព្វាណ; ២-សម្ភោគកាយ គឺកាយដែលប្រកបដោយសិរីសួស្តីរបស់ព្រះពុទ្ធ ស្ថិតនៅក្នុងឋានសួគ៌; ៣-និម្មាណកាយ គឺកាយជាមនុស្ស។

៦–ពួកមហាយានមានជំនឿក្នុងពិធីបុណ្យសាសនា (RITUAL), ពិធីកម្ម (CEREMONY), វេទមន្ត (CHARM), រូបមន្ត (FORMOLAE)។

ក្នុងពេលខាងក្រោយមក ពួកមហាយានបានបង្កើតនូវលទ្ធិអាថ៌កំបាំង, វេទមន្ត, ពិធីដេញខ្មោចបិសាច។ នៅក្នុងសតវត្សរ៍ទី៧(?) ពួកគេបានបង្កើតលទ្ធិមួយទៀត ដែលគេបានឲ្យឈ្មោះថា “តន្ត្រយាន” ជាយានថ្មីសម្រាប់ទៅនិព្វាន។ តន្ត្រយាននេះ ជាក្បួនខ្នាតពន្យល់អំពីអង្គុយស្មិងស្មាធិ៍និងបុណ្យសាសនា ដែលអាចនឹងនាំទៅកាន់និព្វាន ឬទៅជួបនឹងបរមាត្មន។ វិធីសិក្សាផ្លូវតន្ត្រៈនោះ មាន៤យ៉ាង ហៅថា “ក្រិយា” ពិធីបុណ្យសាសនាដែលធ្វើតាមទំនៀម១, “ចយ៉ា” ចរិយាមារយាទ១, “យោគ” ការស្មិងស្មាធិ៍ដោយមុតមាំ១, “អនុត្តរយោគ” ថ្នាក់ប្រសើរនៃយោគ១។ តន្ត្រៈនេះ មានតន្ត្រៈខាងលទ្ធិព្រះឥសូរ, ព្រះនារាយណ៍, ហើយនឹងតន្ត្រៈខាងពុទ្ធសាសនា។ តន្ត្រពុទ្ធសាសនា បង្រៀនបែបដែលអង្គុយស្មិងស្មាធិ៍ខាប

យកពោធិសត្វ ហើយគេអាចតាំងខ្លួនជាពោធិសត្វនៅវេលាក្រោយដែលបានទទួលអភិសេកហើយ។ នៅក្នុងសកលវិទ្យាល័យនាលន្ទានិងសកលវិទ្យាល័យវិក្រមសិលា ពួកសាស្ត្រាចារ្យសុទ្ធតែចេះមន្តអាគម (សិទ្ធ)។

ខាងសាសនាហិណ្ឌូ ក្នុងរូបទេវតាមួយ គេជុំផ្តុំកិរិយាមួយរូបឲ្យ, ជួនកាលគេយកអំណាចសក្តិសិទ្ធិមួយ ហៅថា “សក្តិ” ជានិមិត្តរូប មកធ្វើជាកិរិយានៃអាទិទេពនីមួយៗដែរ ដូចជា នាងបារវតី ជាសក្តិរបស់ព្រះឥសូរ, នាងលក្ស្មី ជាសក្តិរបស់ព្រះវិស្ណុ។ ពុទ្ធសាសនាដែលក្លាយទៅនោះបានចម្លងបែបខុសនេះ យកមកអនុវត្តក្នុងពុទ្ធសាសនា ហើយគេឃើញថា ពោធិសត្វខ្លះនិងព្រះពុទ្ធខ្លះ មានសក្តិដែរ ដូចជា អវលោកិតេស្វរនិងនាងតារា។ គេយល់ថា ការជុំផ្តុំសក្តិនឹងព្រះពោធិសត្វ ឬនឹងព្រះពុទ្ធនោះជាហេតុនាំឲ្យបាននូវសេចក្តីសុខសួស្តីដ៏ឧត្តម។ ហេតុនេះ បានជាគេបង្កើតឲ្យមានកាយទី៤ ហៅថា “មហាសុខកាយ” ឬ “វជ្រកាយ”។ អ្នកណាតាំងខ្លួនធ្វើជាព្រះពុទ្ធឬជាពោធិសត្វ, អ្នកនោះឯង អាចនឹងដល់ទីបរមសុខដោយអំណាចការរួបរួមនឹងសក្តិរបស់ខ្លួនដែរ។ ហេតុនោះ គេបង្កើតវិធីមួយបែបហៅថា “មៃថុន” បញ្ចូលទៅក្នុងសេចក្តីគោរពប្រតិបត្តិនោះថែមទៀត។ គេបានបន្ថែមទ្រឹស្តីទៅលើពិធីនេះទៀតថា “អ្នកដែលតាំងធ្វើជាព្រះពុទ្ធដាច់ខាតហើយ មិនអាចនឹងសៅហ្មងដោយអំពើអាក្រក់អ្វីនីមួយ

ឡើយ"។ គេអាចប្រព្រឹត្តនូវអំពើល្មើសជាឧក្រិដ្ឋធំៗ បានឥតមានទោសអ្វីឡើយ។ នៅឆ្នាំ៦០០នៃគ.ស. នៅដែនកស្មីរ ភូមិភាគហិមពាន្ត អ្នកបួសសុទ្ធតែមានប្រពន្ធទាំងអស់គ្នា។

***

Khmer K21
News & Media Website

ស្រាវជ្រាវដោយៈ ជាច់ សុតឹម